# រឿង បូណា
# ជាកុមារល្អ



ឆ្នាំ ២០១១



បូណាជាកុមារខិតខំរៀនសូត្រណាស់។
អ្នកគ្រូតែងសរសើរបូណារាល់ថ្ងៃ។



នៅផ្ទះបូណាបានជួយធ្វើការ ឪពុកម្ដាយ សព្វគ្រប់ដូចជាដងទឹក ជញ្ជូនអុស។



ជួយស្រោចបន្លែ និងជួយបោសសម្អាតផ្ទះសំបែង។



ដោយឃើញកូនឧស្សាហ៍
ធ្វើការនិងខំរៀនសូត្រដូចនោះ
ម្ដាយបូណាបានទិញ
ស្បែកជើងមួយគូឱ្យជារង្វាន់
ដល់បូណា។ ស្បែកជើងនោះ
ស្អាតណាស់ បាតវាធ្វើអំពី
កៅស៊ូ។



បូណាពាក់ស្បែកជើងថ្មីទៅរៀនរាល់ថ្ងៃ ដោយប្រុងប្រយ័ត្ន ខ្លាចដាច់ខ្សែ ឬប្រឡាក់ភក់។



ថ្ងៃមួយមានភ្លៀងធ្លាក់ខ្លាំង នៅតាមផ្លូវមានទឹកដក់ជាថ្លុកធំៗ។
បូណាត្រូវលោតឆ្លងថ្លុកនោះ តែភ្លាត់ស្មៀតបូណាផុងជើងចូល
ក្នុងភក់ នាំឱ្យប្រឡាក់ស្បែកជើងថ្មី និងខោអាវ។
បូណាចង់យំ។



ពេលនោះមានមិត្តរួមថ្នាក់ជាច្រើន ដើរមកដល់។
បូណាឃើញក៏រាដៃឃាត់មិនឱ្យមិត្តឆ្លងថ្លុក។



មិត្តទាំងអស់បានចាប់ដៃ ទះស្នា អរគុណ និងសរសើរ
ដល់សេចក្តីក្លាហាន និងទឹកចិត្តសប្បុរសល្អរបស់
បូណាជាច្រើន។